EDITORS: Chia Poh Fang,
Amos Khan, Khan Hui Neon,
Leslie Koh
DESIGN & LAYOUT: Felix Xu
COVER & CONTENT PHOTOS:
Shutterstock.com

រក្សាសិទ្ធិគ្រប់យ៉ាងដោយ នំម៉ាណាប្រចាំថ្ងៃ
© 2019 (website: khmer-odb.org)
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

# ខ្ញុំចង់ជឿដែរ

# *ប៉ុន្តែ...*

## ឆ្លើយតបសំណួររបស់អ្នក ដែលទាក់ទងនឹង

## *ព្រះគម្ពីរប៊ីប សាសនា និងអំពើបាប*



**លោកសេន(Shayne)** បានឮដំណឹងល្អអំពីព្រះយេស៊ូវ តាមរយៈកូនស្រីរបស់គាត់ ដែលជាគ្រីស្ទបរិស័ទ។ ពីដំបូង គាត់មិនជឿនាងទេ ហើយក៏បានប្រាប់នាងថា សេចក្ដីជំនឿរបស់នាងមិនសមហេតុផលទាល់តែសោះ។

គាត់ជឿថា គេគ្មានភស្តុតាងណាមួយ ដើម្បីបញ្ជាក់ថា ព្រះពិតជាមានមែននោះឡើយ ហើយក៏គ្មានភស្តុតាងបញ្ជាក់ថា ព្រះយេស៊ូវជាព្រះដែរ។ គាត់ក៏បានសួរនាងថា "តើធ្វើដូចម្ដេចឲ្យកូនអាចដឹងថា អ្វីដែលកូននិយាយនោះគឺជាការពិត?" នាងក៏បានឆ្លើយថា អ្វីៗដែលនាងនិយាយគឺជាការពិត ដោយសម្អាងទៅលើអ្វីដែលមានចែងក្នុងព្រះគម្ពីរ។ ពេលនោះគាត់ក៏បានគ្រវីក្បាល ហើយសួរនាងថា "រឿងអីដែលប៉ាត្រូវជឿព្រះគម្ពីរ? អ្នកនិពន្ធព្រះគម្ពីរជាមនុស្សមែនទេ? រឿងអីដែលប៉ាត្រូវជឿពួកគេ?"

*បន្ទាប់មក លោកសេនក៏បានដឹងថា គាត់មានជម្ងឺមហារីក។ ក្នុងពេលដែលមានវិបត្តិនោះ កូនស្រីរបស់គាត់ក៏បានអធិស្ឋានឲ្យគាត់ ហើយការអធិស្ឋាននេះហាក់ដូចជានាំឲ្យគាត់មានសន្តិភាពនិងការកម្សាន្តចិត្តខ្លះៗ។ គាត់ក៏បានចាប់ផ្ដើមឆ្ងល់ថា គាត់ប្រហែលជាបានគិតខុស ចំពោះព្រះហើយ ហើយគាត់ក៏បានបើកចិត្តស្ដាប់គេនិយាយអំពីជំនឿរបស់គ្រីស្ទបរិស័ទជាបន្ថែមទៀត។ បន្ទាប់ពីគ្រូគង្វាលរបស់កូនស្រីគាត់បានមកសួរសុខទុក្ខគាត់ គាត់ក៏បានគិតថា កូនស្រីគាត់ប្រហែលជានិយាយត្រូវ។ នៅក្នុងជម្រៅចិត្តគាត់ គាត់ថែមទាំងគិតចង់ទទួលជឿព្រះយេស៊ូវ។*

*ប៉ុន្តែ គាត់នៅមានការសង្ស័យដ៏ធំមួយ។ គាត់នៅមិនទាន់ជឿ១០០ភាគរយថា អ្វីដែលព្រះគម្ពីរបានចែងសុទ្ធតែជាការពិតទាំងស្រុងនោះឡើយ។ ម្យ៉ាងទៀត គាត់ឆ្ងល់ថា ហេតុអ្វីគាត់មិនអាចជឿព្រះយេស៊ូវ ដូចដែលគាត់បានជឿសាសនាដទៃទៀត? ហេតុអ្វីជំនឿគ្រីស្ទបរិស័ទ មានភាពខុសប្លែកពីជំនឿសាសនាផ្សេង?*

**តើអ្នកធ្លាប់មានសំណួរដូចលោកសេនទេ?** ពុំនោះទេ តើអ្នកមានការសង្ស័យដទៃទៀត ដែលអ្នកចង់បានការស្រាយបំភ្លឺ មុននឹងធ្វើការសម្រេចចិត្តក្លាយជាគ្រីស្ទបរិស័ទឬទេ?

យើងខ្ញុំយល់អារម្មណ៍របស់អ្នក ហើយយើងខ្ញុំសប្បាយចិត្ត ដែលអ្នកមានសំណួរទាំងនេះ! វាបានបង្ហាញថា អ្នកបានគិតអំពីជំនឿរបស់គ្រីស្ទបរិស័ទ ច្រើនជាងមនុស្សភាគច្រើន និងចង់យល់ឲ្យបានច្បាស់ មុននឹងសម្រេចចិត្តទទួលជឿព្រះ។ យើងខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យបន្តសួរសំណួរ និងស្វែងរកសេចក្ដីពិត។ ព្រះជាម្ចាស់នឹងឆ្លើយតបអ្នក ព្រោះព្រះអង្គស្រឡាញ់អ្នក ព្រះអង្គសព្វព្រះទ័យឲ្យអ្នកស្គាល់ព្រះអង្គ ដើម្បីឲ្យអ្នកអាចទទួលអំណោយនៃសេចក្ដីសង្គ្រោះ ដែលព្រះអង្គប្រទានតាមរយៈព្រះយេស៊ូវ។

ទន្ទឹមនឹងនោះ យើងខ្ញុំសូមលើកឡើងនូវសំណួរមួយចំនួន ដែលគេបានសួរដូចតទៅ :



**ចូរបន្តសួរសំណួរ និងស្វែងរកសេចក្ដីពិត**



ព្រះគម្ពីរគឺជាចំណុចកណ្តាល
នៃជំនឿរបស់គ្រីស្ទបរិស័ទ

## ១. ហេតុអ្វីគ្រីស្ទបរិស័ទនៅតែបន្តនិយាយ អំពីព្រះគម្ពីរប៊ីប?

**ទោះអ្នកបានឮអំពីជំនឿរបស់គ្រីស្ទបរិស័ទ ពីសមាជិកគ្រួសារ ឬមិត្តភក្តិណាម្នាក់ក្តី** ឬក៏បានស្វែងយល់អំពីព្រះ និងព្រះយេស៊ូវ ដោយខ្លួនឯងក្តីអ្នកនឹងកត់សម្គាល់ឃើញថា សេចក្តីជាច្រើនដែលអ្នកបានឮ និងបានអានអំពីទ្រង់ បានបង្អុលបង្ហាញអ្នកឲ្យងាកទៅរកព្រះគម្ពីរប៊ីប ដោយជៀសមិនរួច។ អ្នកប្រហែលជាថែមទាំងបានឮគេនិយាយម្តងហើយម្តងទៀតថា "គឺដោយសារព្រះគម្ពីរបានចែងដូចនេះ"។ ហេតុអ្វីគ្រីស្ទបរិស័ទចូលចិត្តនិយាយច្រើនយ៉ាងនេះ អំពីព្រះគម្ពីរប៊ីប? ហេតុអ្វីព្រះគម្ពីរប៊ីបសំខាន់ចំពោះពួកគេយ៉ាងនេះ?

ព្រះគម្ពីរប៊ីបសំខាន់ ព្រោះព្រះគម្ពីរប៊ីបជាចំណុចកណ្តាលនៃជំនឿរបស់គ្រីស្ទបរិស័ទ។ យើងបានហៅព្រះគម្ពីរប៊ីបថា "ព្រះបន្ទូលព្រះ" ព្រោះព្រះជាម្ចាស់បានប្រើព្រះគម្ពីរ ដើម្បីទំនាក់ទំនងជាមួយយើង។ ដោយសារព្រះគម្ពីរ នោះយើងអាចដឹងថា ព្រះជាម្ចាស់ជាអ្នកបង្កើតចក្រវាល និងបានចាត់ព្រះរាជបុត្រាព្រះអង្គ ព្រះនាមយេស៊ូវ ឲ្យមកសុគតជំនួសយើង ហើយយើងទទួលសេចក្តីសង្គ្រោះ ពេលដែលយើងទទួលជឿព្រះអង្គ។

ហើយព្រះជាម្ចាស់ក៏បានប្រើព្រះគម្ពីរ ដើម្បីបង្រៀនយើង អំពីរបៀបរស់នៅ ឲ្យត្រូវស្តង់ដាររបស់ព្រះអង្គ ហេតុនេះហើយគ្រីស្ទបរិស័ទចំណាយពេលជាច្រើន ក្នុងការអាន និងសិក្សាព្រះគម្ពីរប៊ីប។ លោកប៉ុល ដែលជាសាវ័ករបស់ព្រះយេស៊ូវ បានជួបព្រះយេស៊ូវដោយផ្ទាល់ ហើយបានកត់សម្គាល់ថា "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត"(២ធីម៉ូថេ ៣:១៦)។

## ២. តើខ្ញុំអាចជឿអ្វីៗទាំងអស់ ដែលមានចែងក្នុងព្រះគម្ពីរឬទេ? តើយើងអាចជឿព្រះគម្ពីរឬទេ?

ជាការពិតណាស់ យើងអាចជឿព្រះគម្ពីរប៊ីប។ ព្រោះព្រះគម្ពីរមានប្រភពដើមមកពីព្រះជាម្ចាស់។ ពាក្យក្នុងព្រះគម្ពីរត្រូវបានសរសេរដោយដៃមនុស្ស តែខ្លឹមសារទាំងមូល គឺព្រះទ្រង់បណ្តាលចិត្តឲ្យពួកគេតែងនិពន្ធ។ ព្រះជាអ្នកបង្រៀន និងបណ្តាលចិត្តអ្នកនិពន្ធទាំងនោះ ឲ្យសរសេរអ្វីដែលទ្រង់សព្វព្រះទ័យនឹងមានបន្ទូលប្រាប់យើង។

ម្យ៉ាងទៀត ព្រះគម្ពីរប៊ីបមាន៦៦កណ្ឌ ដែលត្រូវបាននិពន្ធដោយមនុស្សជាង៤០នាក់ ដែលមានដើមកំណើតនៅក្នុងវប្បធម៌ ជាតិសាសន៍ និងសម័យខុសៗគ្នា ក្នុងអំឡុងពេល១៥០០ឆ្នាំ។ ពួកគេបានកត់ទុកនូវព្រឹត្តិការណ៍ក្នុងសម័យរបស់ពួកគេ និងការទំនាក់ទំនងដែលពួកគេមានជាមួយព្រះអង្គ ក៏ដូចជាកត់ទុកនូវអ្វីដែលព្រះទ្រង់បានបើកសម្តែង និងបានធ្វើ។ តែ ទោះបីជាព្រះគម្ពីរត្រូវបាននិពន្ធដោយមនុស្សជាច្រើន នៅសម័យខុសគ្នាក្តី កណ្ឌគម្ពីរទាំងអស់សុទ្ធតែមានភាពស៊ីសង្វាក់គ្នា នៅក្នុងការនិយាយ អំពីព្រះជាម្ចាស់ អំពីសេចក្តីស្រឡាញ់ដែលព្រះអង្គមានសម្រាប់មនុស្ស និងអំពីផែនការដែលព្រះអង្គមានសម្រាប់ចក្រវាល។ បើសិនជាព្រះគម្ពីរគ្រាន់តែជាការប្រឌិតរបស់មនុស្សទេ នោះគេមុខជាមានការពិបាកយ៉ាងខ្លាំង ក្នុងការនិពន្ធព្រះគម្ពីរឲ្យមានភាពស៊ីសង្វាក់យ៉ាងដូចនេះ ។ ម្យ៉ាងទៀត ព្រះគម្ពីរក៏ជាសៀវភៅប្រវត្តិសាស្ត្រផងដែរ។ ជាក់ស្តែង ប្រវត្តិវិទូសម័យទំនើបជាច្រើនបានបញ្ជាក់ថា រឿងប្រវត្តិសាស្ត្រជាច្រើន ដែលបានកត់ទុកក្នុងព្រះគម្ពីរប៊ីប គឺជារឿងពិត។

ជាការពិតណាស់ អ្នកប្រហែលជាពិបាកយល់ចំណុចខ្លះ នៅក្នុងព្រះគម្ពីរប៊ីប។ នេះជារឿងធម្មតាទេ! អ្នកនឹងជួបការបង្រៀន និងពាក្យថ្មីៗជាច្រើន ដែលអ្នកមិនធ្លាប់បានឃើញពីមុន។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលអ្នកបានអាន និងសិក្សា



ព្រះគម្ពីរមួយរយៈហើយ អ្នកនឹងចាប់ផ្ដើមយល់មិនខាន។ ព្រះគម្ពីរមានកណ្ឌជាច្រើន ដែលត្រូវបាននិពន្ធ ដោយមនុស្សដែលរស់នៅក្នុងសម័យផ្សេងគ្នា តែសុទ្ធតែបានបង្កប់នូវសេចក្ដីពិតជាមូលដ្ឋានមួយដូចគ្នា ដែលនិយាយអំពីព្រះជាម្ចាស់ និងអំពីរបៀបដែលព្រះអង្គបានសង្គ្រោះយើងឲ្យរួចពីបាប តាមរយៈការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ។

## ៣. តើព្រះយេស៊ូវ ជាផ្លូវតែមួយ ឆ្ពោះទៅរកការផ្សះផ្សាទំនាក់ទំនងរវាងមនុស្ស និងព្រះឬ? តើខ្ញុំអាចជឿព្រះយេស៊ូវផង និងព្រះដទៃទៀត ក្នុងពេលតែមួយបានទេ?

**អ្នកខ្លះឆ្ងល់ថា ហេតុអ្វីយើងត្រូវតែឈប់ថ្វាយបង្គំព្រះដទៃទៀត ពេលដែលយើងបានសម្រេចចិត្តដើរតាមព្រះអាទិករ។** ពួកគេប្រហែលជានិយាយដូចនេះថា "ផ្លូវទៅនគរស្ថានសួគ៌ មិនមែនមានតែមួយទេ។ ឲ្យតែអ្នកកាន់តាមសាសនារបស់អ្នក ឲ្យបានខ្ជាប់ខ្ជួន អ្នកនឹងទៅនគរស្ថានសួគ៌មិនខាន ទោះអ្នកថ្វាយបង្គំព្រះមួយណាក៏ដោយ"។

ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបាននិយាយសង្កត់ធ្ងន់ថា ព្រះពិត គឺមានតែមួយប៉ុណ្ណោះ គឺព្រះអាទិករ ហើយយើងត្រូវថ្វាយបង្គំព្រះអង្គតែមួយប៉ុណ្ណោះ : ព្រះជាម្ចាស់ជាព្រះពិតតែមួយ គឺគ្មានព្រះឯណាទៀតឡើយ (ចោទិយកថា ៤:៣៥)។

ព្រះគម្ពីរក៏បានចែងយ៉ាងច្បាស់ផងដែរថា វិធីតែមួយ ដើម្បីឲ្យយើងផ្សះផ្សាទំនាក់ទំនងជាមួយព្រះជាម្ចាស់ គឺត្រូវផ្សះផ្សាតាមរយៈព្រះយេស៊ូវ ដែលជាព្រះរាជបុត្រារបស់ព្រះអង្គ។ គឺគ្មានផ្លូវផ្សេងទៀតឡើយ។ យើងមិនអាចទទួលសេចក្ដីសង្គ្រោះ តាមរយៈការជឿអង្គបុគ្គលផ្សេង ដោយធ្វើអំពើល្អ ឬដោយកាន់តាមបទបញ្ញត្តិ ឬការអនុវត្តន៍ផ្សេងឡើយ។ ព្រះយេស៊ូវមានបន្ទូលថា "ខ្ញុំជាផ្លូវ



ព្រះយេស៊ូវមានបន្ទូលថា "ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត។

ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ”(យ៉ូហាន ១៤:៦)។

## ៤. តើជំនឿរបស់គ្រីស្ទបរិស័ទមានអ្វីដែលពិសេស? តើសាសនាទាំងអស់សុទ្ធតែបានបង្រៀនមនុស្សឲ្យធ្វើការល្អមែនទេ?

**អ្នកប្រហែលជាធ្លាប់ឮគេនិយាយថា “ព្រះយេស៊ូវជាអ្នកប្រាជ្ញម្នាក់ ដែលបានបង្រៀនអ្នកដើរតាមទ្រង់ ឲ្យធ្វើជាមនុស្សល្អ មានសីលធម៌”។** បើដូច្នោះមែន តើជំនឿគ្រីស្ទបរិស័ទមានអ្វីខុសប្លែកពីគេ?

តាមពិត ជំនឿរបស់គ្រីស្ទបរិស័ទ មិនមែនជាសាសនាទេ ហើយក៏មិនគ្រាន់តែបានបង្រៀនមនុស្សឲ្យធ្វើល្អប៉ុណ្ណោះឡើយ។ ការដើរតាម ឬជឿព្រះយេស៊ូវ គឺមិនគ្រាន់តែជាការកាន់តាមបទបញ្ញត្តិប៉ុណ្ណោះទេ តែដែលសំខាន់បំផុតនោះ គឺដើម្បីឲ្យយើងបានរួចពីបាប ដើម្បីឲ្យយើងអាចផ្សះផ្សាឲ្យជានឹងព្រះ ហើយមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះអង្គ អស់កល្បជានិច្ច។

យើងអាចព្យាយាមធ្វើអំពើល្អ តែយើងនៅតែមិនអាចធ្វើអំពើល្អឲ្យបានទៀងទាត់ និងមានភាពល្អឥតខ្ចោះ ព្រោះយើងរាល់គ្នាសុទ្ធតែមានបាបពីកំណើត និងចិត្តរបស់យើងក៏មិនល្អឥតខ្ចោះពីកំណើត។ យើងមិនអាចធ្វើឲ្យបានល្អឥតខ្ចោះ ខ្វះមិនដល់ស្តង់ដាដ៏ឥតខ្ចោះរបស់ព្រះជាម្ចាស់ ហើយយើងរាល់គ្នានឹងត្រូវប្រឈមមុខដាក់សេចក្ដីស្លាប់ ដែលជាលទ្ធផលនៃអំពើបាបរបស់យើង។

ហេតុនេះហើយព្រះជាម្ចាស់បានចាត់ព្រះរាជបុត្រាព្រះអង្គ ព្រះនាមយេស៊ូវ ឲ្យយាងចុះមកផែនដី។ ព្រះយេស៊ូវបានមានព្រះជន្មរស់នៅ យ៉ាងល្អឥតខ្ចោះដោយគ្មានបាបទាល់តែសោះ ហើយបានសុគតនៅលើឈើឆ្កាង ដោយទទួលទោសនៃអំពើបាប ជំនួសយើង។ យើងអាចទទួលការអត់ទោសបាបពីព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូវតែមួយអង្គប៉ុណ្ណោះ។



**យើងមិនអាចឈានឲ្យដល់ស្តង់ដាដ៏ល្អឥតខ្ចោះ នៃព្រះដ៏ឥតខ្ចោះបានឡើយ។**

## ៥. ហេតុអ្វីអ្នកថា ខ្ញុំជាមនុស្សមានបាប?

យើងពិបាកនឹងទទួលស្គាល់ថា យើងជាមនុស្សមានបាប។ អ្នកប្រហែលជាចង់សួរថា "ហេតុអ្វីអ្នកថា ខ្ញុំជាមនុស្សមានបាប បើខ្ញុំមិនបានធ្វើអ្វីខុសទេនោះ?" "ខ្ញុំមិនដែលសម្លាប់នរណាម្នាក់។ ខ្ញុំមិនដែលនិយាយកុហក់ ឬបោកប្រាស់គេ ហើយក៏មិនដែលប្រព្រឹត្តខុសច្បាប់ដែរ។ តើខ្ញុំមានបាបដោយរបៀបណា?"

ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរប៊ីបបានចែងថា អំពើបាបមិនគ្រាន់តែជាការធ្វើខុសច្បាប់ ឬខុសសីលធម៌នោះឡើយ តែវាជាការមិនស្ដាប់បង្គាប់ព្រះ និងបដិសេធមិនព្រមឲ្យព្រះអង្គដឹកនាំជីវិតយើង។ យើងរាល់គ្នាសុទ្ធតែបានធ្វើខុសត្រង់ចំណុចនេះ។ ពោលគឺយើងមិនបានស្ដាប់បង្គាប់ព្រះ ឬរស់នៅ តាមផ្លូវដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ ផ្ទុយទៅវិញ យើងបានរស់នៅតាមក្បួនរបស់យើង។ ហេតុនេះហើយបានជាព្រះគម្ពីរចែងថា "គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ"(រ៉ូម ៣:២៣)។

ទោះជាយ៉ាងណាក៏ដោយ បើយើងទទួលជឿព្រះយេស៊ូវដែលជាព្រះរាជបុត្រានៃព្រះ ដោយសារភាពចំពោះព្រះអង្គថា យើងជាមនុស្សមានបាប និងជឿថា ព្រះយេស៊ូវបានសង្គ្រោះយើងឲ្យរួចពីបាប ហើយទូលសូមព្រះអង្គឲ្យអត់ឱនទោសបាបរបស់យើង ហើយទទួលយកអំណោយនៃសេចក្ដីសង្គ្រោះ នោះព្រះជាម្ចាស់នឹងអត់ឱនទោសឲ្យយើងមិនខាន ហើយយើងនឹងបានរួចផុតពីទោស និងអំណាចនៃអំពើបាប។ បានសេចក្ដីថា ព្រះអង្គនឹងរាប់យើងជាសុចរិត ដោយសារជំនឿរបស់យើង ហើយយើងអាចចាប់ផ្ដើមទំនាក់ទំនងជាមួយព្រះអង្គជារៀងរហូត។



**បើយើងសារភាពថា យើងជាមនុស្សមានបាប ហើយជឿថា ព្រះរាជបុត្រាព្រះអង្គ ព្រះនាមយេស៊ូវអាចសង្គ្រោះយើង នោះព្រះអង្គនឹងអត់ទោសឲ្យយើង។**

## តើយើងចង់បានចម្លើយលើសពីនេះទៀតឬ?

**អ្នកប្រហែលជានៅមានចម្ងល់ អំពីជំនឿរបស់គ្រីស្ទបរិស័ទ។** យើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យបន្តសួរសំណួរ និងស្វែងរកសេចក្ដីពិត។ យើងខ្ញុំយល់ថា នេះជាការសម្រេចចិត្តសំខាន់បំផុតក្នុងជីវិតអ្នក ហើយអ្នកប្រហែលជាចង់មានការយល់ដឹងឲ្យកាន់តែច្បាស់។ អ្នកក៏អាចទូលសូមដល់ព្រះ សូមឲ្យព្រះអង្គបើកបង្ហាញសេចក្ដីពិតដល់អ្នក។ ព្រះអង្គរង់ចាំស្ដាប់អ្នកអធិស្ឋានជានិច្ច។ ពុំនោះទេ អ្នកអាចជជែកជាមួយមិត្តភក្តិដែលជាគ្រីស្ទបរិស័ទ ហើយប្រាប់គាត់ អំពីការយល់ឃើញរបស់អ្នក។

បើអ្នកនៅមានការស្ទាក់ស្ទើរ មិនទាន់ចង់ទទួលជឿព្រះយេស៊ូវទេ នោះសូមបន្តស្វែងយល់បន្ថែម។ សូមព្រះអង្គប្រទានប្រាជ្ញា និងការដឹកនាំ ដើម្បីជួយអ្នកឲ្យធ្វើការសម្រេចចិត្តដើរតាមព្រះអង្គ។ ហើយពេលណាអ្នកទទួលជឿព្រះយេស៊ូវ ហើយអធិស្ឋានយាងព្រះអង្គចូលគង់ក្នុងចិត្តអ្នក ព្រះវិញ្ញាណរបស់ព្រះអង្គឲ្យចូលគង់ក្នុងចិត្តអ្នក ដើម្បីដឹកនាំអ្នក ក្នុងការធ្វើដំណើរនៃសេចក្ដីជំនឿ។ ព្រះអង្គមានបន្ទូលសន្យាថា "ព្រះអង្គនឹងមិនបោះបង់ចោលយើងឲ្យនៅកំព្រាឡើយ ... ហើយព្រះវិញ្ញាណនឹងបង្រៀនយើងរាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលព្រះអង្គបានប្រាប់ដល់យើងរាល់គ្នាដែរ"(យ៉ូហាន ១៤:១៨-២៦)។





**បើអ្នកមានអារម្មណ៍ថា អ្នកបានត្រៀមចិត្តដើម្បីដើរតាមព្រះយេស៊ូវ នោះយើងខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យធ្វើការសម្រេចចិត្ត នៅពេលឥឡូវនេះ។**

## ការសម្រេចចិត្ត

បើសិនជាអ្នកនៅមានសំណួរ អំពីជំនឿរបស់គ្រីស្ទបរិស័ទ យើងខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យស្វែងយល់សេចក្តីពិតជាមូលដ្ឋាន នៃដំណឹងល្អដែលមានដូចតទៅ :

- ព្រះជាម្ចាស់បានបង្កើតយើងមក ដើម្បីឲ្យយើងមានទំនាក់ទំនងនៃសេចក្តីស្រឡាញ់ ជាមួយព្រះអង្គ។
- ប៉ុន្តែ យើងម្នាក់ៗបានងាកបែរចេញពីព្រះអង្គ ដោយរស់នៅតាមស្តង់ដាររបស់យើង ហើយបានបដិសេធសិទ្ធិអំណាចរបស់ព្រះអង្គ។
- ការមិនស្តាប់បង្គាប់នេះ គឺជាអំពើបាប ដែលទោសរបស់វា គឺជាសេចក្តីស្លាប់។
- ប៉ុន្តែ ព្រះជាម្ចាស់បានប្រទាននូវដំណោះស្រាយមួយ ដោយចាត់ព្រះរាជបុត្រាព្រះអង្គ ព្រះយេស៊ូវគ្រីស្ទ ឲ្យសុគតជំនួសយើង។
- ព្រះយេស៊ូវបានសុគត តែបីថ្ងៃក្រោយមក ព្រះអង្គមានព្រះជន្មរស់ឡើងវិញ គឺបានបង្ហាញថា ព្រះជាម្ចាស់បានទទួលយកដង្វាយលោះបាប ដែលព្រះអង្គបានថ្វាយជំនួសយើង។
- នេះជាអំណោយនៃសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ : យើងមិនសមនឹងទទួលការអត់ទោសពីព្រះអង្គទេ ហើយយើងក៏មិនអាចស្វែងរកការអត់ទោស ដោយអាងលទ្ធភាពខ្លួនឯងឡើយ គឺមានតែតាមរយៈព្រះគុណព្រះអង្គប៉ុណ្ណោះ ដែលយើងអាចទទួលការអត់ទោសបាប និងសេចក្តីសង្គ្រោះ។

អ្នកអាចសម្រេចចិត្តទទួលជឿព្រះយេស៊ូវ នៅពេលឥឡូវនេះបាន! អ្នកអាចអធិស្ឋានទទួលជឿព្រះអង្គ តាមលំនាំខាងក្រោមនេះ។ ពាក្យពេចន៍ខាងក្រោមនេះ គឺគ្រាន់តែជាលំនាំនៃការអធិស្ឋាន តែដែលសំខាន់បំផុតនោះ គឺអ្នកបានអធិស្ឋានចេញចិត្តរបស់អ្នក :

*ព្រះអម្ចាស់យេស៊ូវអើយ ទូលបង្គំត្រូវការព្រះអង្គ។ សូមអរព្រះគុណព្រះអង្គ ដែលបានសុគតនៅលើឈើឆ្កាងជំនួសទូលបង្គំ។ ទូលបង្គំសូមបើកចិត្តទូលបង្គំ ទទួលព្រះអង្គធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានអត់ទោសបាបឲ្យទូលបង្គំ ហើយប្រទានជីវិតអស់កល្បជានិច្ចដល់ទូលបង្គំ។ សូមព្រះអង្គយាងមកសោយរាជ្យ លើបល្ល័ង្កជីវិតទូលបង្គំ។ សូមកែច្នៃទូលបង្គំឲ្យទៅជាមនុស្សដែលព្រះអង្គសព្វព្រះហឫទ័យ អាម៉ែន។*

ព្រះជាម្ចាស់តែងតែស្តាប់យើងជានិច្ច ដូចនេះ អ្វីដែលយើងត្រូវធ្វើ នោះគឺត្រូវនិយាយទៅកាន់ព្រះអង្គ គឺហាក់ដូចជាព្រះអង្គកំពុងតែនៅពីមុខយើង។ បើសិនជាអាច សូមឲ្យមិត្តភក្តិជាគ្រីស្ទបរិស័ទ អធិស្ឋានជាមួយអ្នក។

បើសិនជាលោកអ្នកចង់ស្វែងយល់បន្ថែមអំពីព្រះយេស៊ូវ និងអំពីការអ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នក សូមទាញយក ឬdownload សៀវភៅ រឿងនៃក្តីសង្ឃឹម តាមអាស័យដ្ឋាន https://khmer-odb.org/ds/story-of-hop/

